**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ...១៤៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១០០៥ អនក្រ.តត ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

Downloaded from http://www.khmerlaws.com

## ស ម្រេ ច

**មាត្រា១:** ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈសម្រាប់អាណត្តិទី២ ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ជុច ភឿន** | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | **ប្រធានកិត្តិយស** |
| ២- ឯកឧត្តម **សោម សុគន្ធ** | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | **ប្រធាន** |
| ៣- ឯកឧត្តម បណ្ឌិតវង្ស **តិច សំណាង** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | **សមាជិក** |
| ៤- ឯកឧត្តម **ម៉ក់ សម្បត្តិ** | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | **សមាជិក** |
| ៥- ឯកឧត្តម **មុខ សុវត្ថិ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | **សមាជិកស្វ័យប្រវត្តិ** |
| ៦- ឯកឧត្តម **ម៉ក់ ដារិន** | តំណាងក្រសួងអប់រំ យុវជន និងកីឡា | **សមាជិក** |
| ៧- លោក **គុយ សារុន** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | **សមាជិក** |
| ៨- លោក **ស៊ូ ចិន្តា** | តំណាងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | **សមាជិកស្វ័យប្រវត្តិ** |

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

Downloaded from http://www.khmerlaws.com